**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខ:១៣១
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២
សាលក្រមរដ្ឋប្បវេណីលេខ:០១ "ឈ"
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

**-ដើមចោទ**ឈ្មោះ [redacted] វីណា ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន[redacted]។

**-អ្នកតំណាងដោយអាណត្តិៈ**លោកមេធាវី [redacted] អត្តលេខ:៩៨៧ លោកស្រីមេធាវី [redacted] អត្តលេខ:២៤៥០T លោកមេធាវី [redacted] អត្តលេខ:២៥០៨T និងលោកមេធាវី [redacted] អត្តលេខ:២៣៥៣T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យមេធាវី [redacted] អាសយដ្ឋានស្ថិតនៅ[redacted]។

**-ចុងចម្លើយ**ឈ្មោះ [redacted] សៅរី ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន[redacted]។

## I.អង្គហេតុ និងចំណុចវិវាទ

**ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញៈ**

១-លែងលះពីប្តីឈ្មោះ [redacted] សៅរី។

២-សុំអំណាចមេបាលើកូន ០២នាក់

ទី១.ឈ្មោះ [redacted] ស៊ីយុ ភេទប្រុស អាយុ ០៦ឆ្នាំ

ទី២.ឈ្មោះ [redacted] ចាន់ឌីម៉ា ភេទស្រី អាយុ ០៤ឆ្នាំ។

៣-សុំទាមទារអាហារកិច្ចចិញ្ចឹមកូន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ក្នុង ០១ខែ។

៤-សុំទាមទារឱ្យជួយសងប្រាក់បំណុលធនាគារចំនួន ២៥.០០០(ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិក។

៥-សុំគ្រង់គ្រងរថយន្តម៉ាក កូរ៉េ ទម្ងន់ ១តោនកន្លះ ផ្លាកលេខ ក្រចេះ ២A-០៥៧១។



Scanned with CamScanner

## ខ-ការសង្ខេបអំពីរឿងក្តី

រឿងក្តីនេះជារឿងក្តីដែលដើមចោទបានប្តឹងទាមទារលែងលះពីចុងចម្លើយ សុំសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ ឈ្មោះ [redacted] ស៊ីយុ ភេទប្រុស អាយុ ០៦ឆ្នាំ និងឈ្មោះ [redacted] ចាន់នីម៉ា ភេទស្រី អាយុ ០៤ឆ្នាំ សុំទាមទារអាហារកិច្ចចិញ្ចឹមកូន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ក្នុង ០១ខែ សុំទាមទារឱ្យជួយសងប្រាក់បំណុលធនាគារចំនួន ២៥.០០០(ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិក និងសុំគ្រប់គ្រងរថយន្តម៉ាក កូរ៉េ ទម្ងន់ ១តោនកន្លះ ផ្លាកលេខ ក្រចេះ ២A-០៥៧១។ ផ្អែកលើការរស់នៅជាមួយគ្នាជាប្តីប្រពន្ធមិនចុះសម្រុងនឹងគ្នា ចុងចម្លើយលួចលាក់មានស្រីថ្មី ជាហេតុធ្វើឱ្យដើមចោទជាប្រពន្ធអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។

## គ-ចំណុចវិវាទ

-តើមានអត្ថិភាពនៃប្រាក់ជាទ្រព្យសម្បត្តិរួមដែលជាផលបានពីការលក់រថយន្តម៉ាក កូរ៉េ ទម្ងន់ ១តោនកន្លះ ផ្លាកលេខ ក្រចេះ ២A-០៥៧១ ប្រមាណ ៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក និងប្រាក់ចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក ជាចំណែកនៃទ្រព្យសម្បត្តិរួម ដែលចុងចម្លើយ និងដើមចោទបានចំណាយធ្វើផ្ទះនៅលើដីរបស់ដើមចោទដែលត្រូវបែងចែកដែរឬទេ?

-តើមានអត្ថិភាពនៃបំណុលរួមដែលដើមចោទ និងចុងចម្លើយបានខ្ចីពីធនាគារប្រៃសណីយ៍ចំនួន ២៥.០០០(ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ហើយពេលបែកលំនៅពីគ្នាប្រាក់ដែលនៅជំពាក់ចំនួន ១៦.០០០(មួយម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក និងត្រូវបានចុងចម្លើយបង់ផ្តាច់ចុងក្រោយចំនួន ១២.០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ដែលត្រូវបែងចែកដែរឬទេ?

-តើមានអត្ថិភាពនៃបំណុលរួមដូចដែលចុងចម្លើយបានអះអាងថាខ្លួន និងដើមចោទបានពឹងម្តាយឈ្មោះ [redacted] មីន និងប្អូនបង្កើតឈ្មោះ [redacted] ម៉ក់នាង ខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវែលខាំចំនួន ៣.២០០(បីពាន់ពីររយ)ដុល្លារអាមេរិក មកបង្គ្រប់ថ្លៃទិញរថយន្តដែរឬទេ?

# II.ការអះអាងរបស់គូភាគី

## ក-អង្គហេតុដែលអះអាងដោយដើមចោទ

-ដើមចោទឈ្មោះ [redacted] វីណា បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ២០១៥ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ២៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥។ ក្រោយពីរៀបអាពាហ៍ពិពាហ៍រួច ដើមចោទ និងចុងចម្លើយមានកូនចំនួន ០២នាក់ ឈ្មោះ [redacted] ស៊ីយុ ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ចាន់នីម៉ា ភេទស្រី កើតថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រង និងចិញ្ចឹមបីបាច់។ ចំពោះទ្រព្យរួមមានមានរថយន្តម៉ាក កូរ៉េ ទម្ងន់ ១តោនកន្លះ ផ្លាកលេខ ក្រចេះ ២A-០៥៧១ និងបំណុលរួមមានប្រាក់កម្ចីចំនួន ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក។ អំឡុងរស់នៅជាប្តីប្រពន្ធ ចុងចម្លើយលួចលាក់មានស្រីថ្មី និងបានរៀបអាពាហ៍អាពាហ៍ផងដែរ ទើបធ្វើឱ្យដើមចោទដាក់ពាក្យបណ្តឹងលែងលះតែម្តង។

## ខ-អង្គហេតុដែលអះអាងដោយចុងចម្លើយ

-ចុងចម្លើយឈ្មោះ [redacted] សៅរី បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ចុងចម្លើយ និងដើមចោទបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ

២០១៥ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ២៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥។ ក្រោយពីរៀបអាពាហ៍ពិពាហ៍រួច ចុងចម្លើយ និងដើមចោទមានកូនចំនួន ០២នាក់ ឈ្មោះ [redacted] ស៊ីយុ ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ចាន់ឌីម៉ា ភេទស្រី កើតថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។ ចំពោះទ្រព្យរួមមានមានរថយន្តម៉ាក កូរ៉េ ទម្ងន់ ១តោនកន្លះ ផ្លាកលេខ ក្រចេះ ២A-០៥៧១ និងបំណុលរួមមានប្រាក់កម្ចីចំនួន ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក។

## III.ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ដើមចោទ**

**១-១.**ឯកសារ $X_1$ សំបុត្រអាពាហ៍ពិពាហ៍លេខ២៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] សៅរី និងឈ្មោះ **ង៉ែត វីណា** ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអូរសារាយ។

**១-២.**ឯកសារ $X_2$ សំបុត្របញ្ជាក់កំណើតលេខ២៧០ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **ចាន់ឌីម៉ា** ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអូរសារាយ។

**១-៣.**ឯកសារ $X_3$ សំបុត្រកំណើតលេខ៥១ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] **ស៊ីយុ** ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអូរសារាយ។

**១-៤.**ឯកសារ $X_4$ ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០។

**១-៥.**ឯកសារ $X_5$ តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨។

**១-៦.**ឯកសារ $X_6$ កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០។

**១-៧.**ឯកសារ $X_7$ ឯកសាររូបថតចំនួន ០៥សន្លឹក។

**២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

គ្មាន។

## សំអាងហេតុ

**១-ស្តីពីការទាមទារទី១៖ការលែងលះ**

**១-១.**តាមភស្តុតាងឯកសារ$X_1$ ព្រមទាំងការអះអាងរបស់ដើមចោទ និងចុងចម្លើយដែលបានអះអាងថាពួកគេបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណីនៅឆ្នាំ២០១៥ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ដូចមាននៅក្នុងសំបុត្រអាពាហ៍ពិពាហ៍លេខ២៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ធ្វើឱ្យតុលាការទទួលស្គាល់បានថា ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី នៅឆ្នាំ២០១៥ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ពិតប្រាកដមែន។ ការណ៍ដែលដើមចោទ និងចុងចម្លើយរស់នៅជាមួយគ្នាដោយបានចុះអាពាហ៍ពិពាហ៍នឹងគ្នាបែបនេះ មានន័យថាដើមចោទ និងចុងចម្លើយមានជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា គឺរស់នៅជាមួយគ្នាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

**១-២.**ដើមចោទ និងចុងចម្លើយបានអះអាងដូចគ្នាថា ការរស់នៅរបស់ពួកគេមិនចុះសម្រុងនឹងគ្នាបណ្តាលឱ្យអស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នា។ តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយនេះ ធ្វើឱ្យតុលាការទទួលស្គាល់ថា ចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន ដែលនេះបង្ហាញឱ្យឃើញថាការទាមទារលែងលះរបស់ដើមចោទ គឺស្របតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា។



Scanned with CamScanner

**២-ស្ដីពីការទាមទារទី២៖ការសុំសិទ្ធិអំណាចមេបាលើកូន**

២-១.តាមភស្តុតាងឯកសារ$X_{២}$និង $X_{៣}$ តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយដែលបានអះអាងដូចគ្នាថា ការស់នៅជាមួយគ្នាជាប្តីប្រពន្ធ ពួកគេមានកូនចំនួន ០២នាក់ ឈ្មោះ [redacted] ស៊ីយុ ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ចាន់ឌីម៉ា ភេទស្រី កើតថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ នោះ ធ្វើឱ្យតុលាការទទួលស្គាល់ថា ក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយពិតជាមានកូនចំនួន ០២នាក់ មានឈ្មោះ [redacted] ស៊ីយុ ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ចាន់ឌីម៉ា ភេទស្រី កើតថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ពិតប្រាកដមែន។

២-២.ដើមចោទទាមទារសុំសិទ្ធិអំណាចមេបាលើកូនជាអនីតិជនឈ្មោះ [redacted] ស៊ីយុ ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ចាន់ឌីម៉ា ភេទស្រី កើតថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។ ការទាមទាររបស់ដើមចោទនេះ ចុងចម្លើយក៏ឯកភាពដែរ។ ដោយដើមចោទ និងចុងចម្លើយបានព្រមព្រៀងឯកភាពគ្នាដូចនេះ ហើយដើមចោទក៏មានលទ្ធភាពគ្រប់គ្រង ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យកូនបានសិក្សារៀនសូត្រ ដើម្បីមានអនាគតល្អ និងក្លាយជាពលរដ្ឋល្អក្នុងសង្គមបាននោះ យោងតាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៣-ស្ដីពីការទាមទារទី៣៖សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងថែរក្សាកូន**

-ដើមចោទបានទាមទារឱ្យចុងចម្លើយផ្តល់សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក។ នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ដើមចោទយល់ព្រមលះបង់ការទាមទារនេះពីចុងចម្លើយហើយ។ ដូចនេះគប្បីតុលាការគោរពតាមការចាត់ចែងរបស់ភាគី។

**៤-ស្ដីពីការទាមទារទី៤៖អំពីបំណុល**

-ដើមចោទ ក៏ដូចជាចុងចម្លើយបានទាមទារឱ្យតុលាការសម្រេចពីការទទួលបន្ទុកលើបំណុលរបស់អ្នកទាំងពីរ។ យោងតាមមាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី ឃើញថា ទ្រព្យសម្បត្តិរួមសំដៅតែលើទ្រព្យសកម្មមិនសំដៅលើទ្រព្យអកម្ម(បំណុល)ទេ។ ដូចនេះការទាមទាររបស់ដើមចោទ និងចុងចម្លើយពាក់ព័ន្ធនឹងបំណុលមិនមែនជាកម្មវត្ថុនៃការទាមទារបែងចែកក្នុងរឿងក្តីលែងលះនេះទេ ហេតុនេះតុលាការមិនលើកយកបំណុលនេះ មកធ្វើការសម្រេចសេចក្តីនោះឡើយ។

**៥-បន្ទុកនៃប្រាក់ប្រដាប់ក្តី**

-នៅក្នុង "រឿងក្តីលែងលះនេះ" ដើមចោទយល់ព្រមទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ហេតុនេះតុលាការសម្រេចតាមការទាមទារ។

## សេចក្តីសម្រេចបញ្ចប់

១.ដើមចោទឈ្មោះ [redacted] វីណា លែងលះពីចុងចម្លើយឈ្មោះ [redacted] សៅរី។

២.កំណត់ថាដើមចោទឈ្មោះ [redacted] វីណា ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ស៊ីយុ ភេទប្រុស កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ និងឈ្មោះ [redacted] ចាន់ឌីម៉ា ភេទស្រី កើតថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

៣.ច្រានចោលការទាមទារត្រង់ចំណុច៣ ចំណុច៤ និងចំណុច៥ ខ្លឹមសារនៃសាលក្រមដែលដើមចោទឈ្មោះ [redacted] វីណា ទាមទារឱ្យតុលាការចេញ។



Scanned with CamScanner

៤.ប្រាក់ប្រដាប់ក្តីឱ្យដើមចោទជាអ្នកទទួលបន្ទុក។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៦រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

កំពង់ស្ពឺ,ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner